# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំ
## ស្តីពី
## ទម្រង់ពាក្យស្នើសុំបើកគណនីជួញដូរនិងកិច្ចព្រមព្រៀងអតិថិជនសម្រាប់ការជួញដូរឧបករណ៍និស្សន្ទ

ចែករំលែកដោយៈ

សមាគមឈ្មួញជើងសាឧបករណ៍និស្សន្ទនៅកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ:....០០៣/១៧.....គ.ម.ក./គ.ណ.ន.

រាជធានីភ្នំពេញ, ថ្ងៃច័ន្ទ ៩ កើត ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១
ត្រូវនឹង ថ្ងៃទី២៧ ខែវិច្ឆិកា គ.ស ២០១៧

# គោលការណ៍ណែនាំ
# ស្តីពី
# ទម្រង់ពាក្យស្នើសុំបើកគណនីជួញដូរ និងកិច្ចព្រមព្រៀងអតិថិជន សម្រាប់ការជួញដូរឧបករណ៍និស្សន្ទ

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន,អនុក្រឹត្យលេខ៥៤ អនក្រ.បក. ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន,ប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹងនិងធានាឱ្យបានការអនុវត្តប្រកបដោយប្រសិទ្ធភាពគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) សម្រេចចេញគោលការណ៍ណែនាំស្តីពីទម្រង់ពាក្យស្នើសុំបើកគណនីជួញដូរ និងកិច្ចព្រមព្រៀងអតិថិជនសម្រាប់ការជួញដូរឧបករណ៍និស្សន្ទ ដូចខាងក្រោម÷

មុនពេលធ្វើប្រតិបត្តិការជាមួយអតិថិជន ឬក្នុងនាមអតិថិជន ឈ្មួញជើងសាឧបករណ៍និស្សន្ទតាមរយៈភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវបំពេញកាតព្វកិច្ចតាមច្បាប់ក្នុងការសិក្សាឱ្យបានច្បាស់លាស់ពីព័ត៌មានទាក់ទងនឹងអតិថិជន និងបំពេញតាមទម្រង់ពាក្យស្នើសុំបើកគណនីដែលមានក្នុងឧបសម្ព័ន្ធ១ នៃគោលការណ៍ណែនាំនេះ ដោយត្រូវគោរពតាមគោលការណ៍ស្គាល់អតិថិជន (Know Your Client)។ ឈ្មួញជើងសាឧបករណ៍និស្សន្ទតាមរយៈភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ត្រូវសិក្សាស្វែងយល់ព័ត៌មានទាក់ទងនឹងអតិថិជនដោយផ្ទាល់ជាមួយអតិថិជន ដែលព័ត៌មានទាំងនោះមានជាអាទិ៍ដូចខាងក្រោម÷

១- ស្ថានភាពហិរញ្ញវត្ថុ និងសេចក្តីត្រូវការរបស់អតិថិជន។

២- គោលដៅវិនិយោគរបស់អតិថិជន។

៣- ឥរិយាបទអតិថិជនចំពោះហានិភ័យដែលអាចកើតមាន។

៤- បទពិសោធន៍ និងចំណេះដឹងនៃការវិនិយោគរបស់អតិថិជន។

ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ត្រូវផ្តល់ប្រឹក្សាអំពីការវិនិយោគលើឧបករណ៍និស្សន្ទដល់អតិថិជនដោយផ្អែកលើមូលដ្ឋានត្រឹមត្រូវ និងសមហេតុផល និងត្រូវផ្អែកលើគោលការណ៍ស្គាល់អតិថិជន និងព័ត៌មានទាក់ទងនឹងអតិថិជនដូចបានបញ្ជាក់ខាងលើ។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវចាត់តាំងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទដើម្បីទទួលខុសត្រូវលើប្រតិបត្តិការបើកគណនី និងគ្រប់គ្រងប្រតិបត្តិការគណនី។ ការអនុញ្ញាតលើការបើកគណនីត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបានរក្សាទុកនៅក្រុមហ៊ុន។ វិនិយោគិនអាចធ្វើប្រតិបត្តិការដំបូងលើគណនីនេះបានលុះត្រាតែគណនីនេះត្រូវបានអនុញ្ញាតឱ្យបើក។ វិនិយោគិនអាចបើកគណនីជួញដូរឧបករណ៍និស្សន្ទបានមួយនៅឈ្មួញជើងសាឧបករណ៍និស្សន្ទមួយ។

ជាមួយគ្នានេះ មុននឹងទទួលបុគ្គលណាម្នាក់ជាអតិថិជន ឈ្មួញជើងសាឧបករណ៍និស្សន្ទតាមរយៈភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយអតិថិជន តាមទម្រង់ដូចមានក្នុងឧបសម្ព័ន្ធ២ នៃគោលការណ៍ណែនាំនេះ។ មុនចុះហត្ថលេខាជាមួយអតិថិជន ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទដែលទាក់ទងដោយផ្ទាល់ជាមួយអតិថិជនត្រូវពន្យល់លម្អិតពីខ្លឹមសារនៃកិច្ចព្រមព្រៀង វិធីសាស្ត្រនៃការជួញដូរ និងហានិភ័យដែលអាចកើតមានដល់អតិថិជន។

មុនប្រើប្រាស់ ឬកែប្រែទម្រង់ពាក្យស្នើសុំបើកគណនី និងកិច្ចព្រមព្រៀងអតិថិជន ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ គ.ម.ក.។

ឈ្មួញជើងសាឧបករណ៍និស្សន្ទ និងភ្នាក់ងារឧបករណ៍និស្សន្ទមិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការគណនីឆន្ទានុសិទ្ធិដោយគ្មានការអនុញ្ញាតពី គ.ម.ក.។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវផ្ញើជូន គ.ម.ក. ជាប្រចាំថ្ងៃតាមរយៈសារអេឡិចត្រូនិចរបស់នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ derivative@secc.gov.kh នូវរបាយការណ៍ស្តីពីការបើក និងបិទគណនីជួញដូររបស់អតិថិជននីមួយៗ ដោយមានព័ត៌មានអប្បបរមាដូចជា កាលបរិច្ឆេទនៃការបើក ឬបិទគណនី លេខអត្តសញ្ញាណសំគាល់អតិថិជន លេខគណនីជួញដូរ ឈ្មោះរបស់អតិថិជន សញ្ជាតិ លេខអត្តសញ្ញាណប័ណ្ណ ឬលេខលិខិតឆ្លងដែន លេខទូរសព្ទ អ៊ីម៉ែល និងអាសយដ្ឋាន។ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវផ្តល់របាយការណ៍នេះ សរុបប្រចាំខែជាលាយលក្ខណ៍អក្សរជូន គ.ម.ក. មិនឱ្យលើសពីថ្ងៃទី១០ នៃខែបន្ទាប់។

គណៈកម្មការមូលបត្រកម្ពុជា

### ឧបសម្ព័ន្ធ ១ នៃគោលការណ៍ណែនាំលេខ.០០៣/១៧
### ស្ដីពីទម្រង់ពាក្យស្នើសុំបើកគណនីជួញដូរ និងកិច្ចព្រមព្រៀងអតិថិជនសម្រាប់ការជួញដូរឧបករណ៍និស្សន្ទ
### ចុះថ្ងៃទី២៧...ខែ..វិច្ឆិកា..ឆ្នាំ២០១៧...

## ពាក្យស្នើសុំបើកគណនីជួញដូរ

ក. <u>ពាក្យស្នើសុំបើកគណនីជួញដូរឧបករណ៍និស្សន្ទ (សម្រាប់រូបវន្តបុគ្គល)</u>

| | | |
|---|---|---|
| ឈ្មោះឈ្មួញជើងសាឧបករណ៍និស្សន្ទ........................ | កាលបរិច្ឆេទនៃការស្នើសុំ | លេខគណនី |
| ឈ្មោះភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ...................... | .................................. | ........................... |

**១. ព័ត៌មានអតិថិជន**

ឈ្មោះអតិថិជន (គោត្តនាម និងនាម) ....................................... ជាអក្សរឡាតាំង.......................................

ធ្លាប់បានផ្លាស់ប្ដូរឈ្មោះពីមុន ☐មិនធ្លាប់ ☐ ធ្លាប់ (បើធ្លាប់សូមភ្ជាប់ឯកសារបញ្ជាក់.......................................)

ថ្ងៃ/ខែ/ឆ្នាំកំណើត........................ | សញ្ជាតិ.................................. | ភេទ ☐ប្រុស ☐ស្រី

លេខអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែន................. ចេញដោយ............ កាលបរិច្ឆេទផុតសុពលភាព...............

អាសយដ្ឋានបច្ចុប្បន្ន..................................................................................................................

អាសយដ្ឋានអចិន្ត្រៃយ៍...................................................................................................................

លេខទូរសព្ទទំនាក់ទំនងផ្ទាល់ខ្លួន............................................ អ៊ីម៉ែល ..............................................

មុខរបរ/តួនាទី .............. ឈ្មោះទីកន្លែងធ្វើការ............ ប្រភេទអាជីវកម្ម................. អាសយដ្ឋានទីកន្លែងធ្វើការ ........................................................................... លេខទូរសព្ទកន្លែងធ្វើការ.....................រយៈពេលបម្រើការងារ..........................................................................

**២. សហព័ទ្ធ**

ឈ្មោះសហព័ទ្ធ (គោត្តនាម និងនាម)................................ ជាអក្សរឡាតាំង ......................................

ធ្លាប់បានផ្លាស់ប្ដូរឈ្មោះពីមុន ☐មិនធ្លាប់ ☐ ធ្លាប់ (បើធ្លាប់សូមភ្ជាប់ឯកសារបញ្ជាក់....................................)

ថ្ងៃ/ខែ/ឆ្នាំកំណើត............................................... | សញ្ជាតិ..................................................

លេខទូរសព្ទទំនាក់ទំនងផ្ទាល់ខ្លួន............................ អ៊ីម៉ែល................................................

ឈ្មោះទីកន្លែងធ្វើការ....................................... | តួនាទី....................................................

អាសយដ្ឋានកន្លែងធ្វើការ .......................................................................................................

**៣. កម្រិតវប្បធម៌ទូទៅ និងការយល់ដឹងពីឧបករណ៍និស្សន្ទរបស់អតិថិជន**

១. កម្រិតសិក្សា÷ ☐បណ្ឌិត ☐អនុបណ្ឌិត ☐បរិញ្ញាបត្រ ☐ទាបជាងបរិញ្ញាបត្រ.......... ជំនាញ.............

២. ចំណេះដឹងអតិថិជនទាក់ទងនឹងឧបករណ៍និស្សន្ទ÷

☐ អតិថិជនបានចូលរួមវគ្គបណ្តុះបណ្តាលទាក់ទងនឹងផលិតផលឧបករណ៍និស្សន្ទ។

☐ អតិថិជនធ្លាប់/កំពុងមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងផលិតផលឧបករណ៍និស្សន្ទ។

☐ អតិថិជនធ្លាប់/កំពុងធ្វើការជួញដូរឧបករណ៍និស្សន្ទ។

☐ អតិថិជនមិនធ្លាប់មានបទពិសោធន៍ជួញដូរឧបករណ៍និស្សន្ទទេ។

## ៤.គោលដៅនៃការវិនិយោគ

☐ការវិនិយោគរយៈពេលខ្លី ☐ការវិនិយោគរយៈពេលវែង ☐ផ្សេងទៀត

## ៥. បទពិសោធន៍វិនិយោគ

បទពិសោធន៍នៃការជួញដូរនៅក្នុងទីផ្សារហិរញ្ញវត្ថុដទៃទៀត ☐មិនមាន ☐មាន

| | | | |
|---|---|---|---|
| ១. ឈ្មោះទីផ្សារ...................... | ប្រភេទផលិតផល............. | ប្រទេស.............. | ឆ្នាំនៃការវិនិយោគ.. ឆ្នាំ |
| ២. ឈ្មោះទីផ្សារ...................... | ប្រភេទផលិតផល............. | ប្រទេស.............. | ឆ្នាំនៃការវិនិយោគ.. ឆ្នាំ |

## ៦. ចំណូលប្រចាំខែ

ចំណូលប្រចាំខែ ☐មិនមាន ☐មាន

ចំណូលប្រចាំខែបន្ទាប់ពីដកពន្ធ (រៀល)

☐ 0 - ១.000.000

☐ ១.000.00១ - ២.000.000

☐ ២.000.00១ - ៣.000.000

☐ ៣.000.00១ - ៤.000.000

☐ ច្រើនជាង ៤.000.000

ប្រភពចំណូលផ្សេងទៀត ប្រសិនបើមាន

☐ ភាគលាភ/ការប្រាក់ពីមូលបត្រកម្មសិទ្ធិ/សញ្ញាបណ្ណ

☐ ភាគលាភ/ការប្រាក់ពីក្រុមហ៊ុនផ្ទាល់ខ្លួន

☐ ការប្រាក់ពីធនាគារ

☐ ផ្សេងទៀត........................

## ៧. វិនិយោគិនគុណវុឌ្ឍិ

តើអតិថិជនជាវិនិយោគិនគុណវុឌ្ឍិដែរ ឬទេ?

☐មិនមែន ☐មែន

បើមែន សូមបញ្ជាក់÷

| |
|---|
| ☐អតិថិជនមានទ្រព្យសកម្មសុទ្ធសរុបយ៉ាងតិច ១.០០០.០០០.០០០ រៀល ឬ<br>☐អតិថិជនមានចំណូលប្រចាំឆ្នាំយ៉ាងតិច ៨០.០០០.០០០ រៀល ឬ<br>☐អតិថិជនធ្លាប់បានចូលរួមវិនិយោគក្នុងវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា យ៉ាងតិច ១០០.០០០.០០០ រៀល |
| **៨. បុគ្គលជាប់ទាក់ទង (សូមភ្ជាប់មកជាមួយអត្តសញ្ញាណបណ្ណ/ លិខិតឆ្លងដែន ថតចម្លងរបស់បុគ្គលជាប់ទាក់ទងនោះ)** |
| បុគ្គលទទួលបានការអនុញ្ញាត ☐គ្មាន ☐មាន (សូមបញ្ជាក់គោត្តនាម និងនាម)............................................ |
| ទំនាក់ទំនងរវាងបុគ្គលទទួលបានការអនុញ្ញាត នឹងម្ចាស់គណនី............................................................ |
| បុគ្គលទទួលបានផលប្រយោជន៍ (Beneficial Owner): ☐ផ្ទាល់ខ្លួន ☐បុគ្គលផ្សេង (បញ្ជាក់គោត្តនាម និងនាម).......... |
| បុគ្គលគ្រប់គ្រង (Controlling Person): ☐ផ្ទាល់ខ្លួន ☐បុគ្គលផ្សេង (បញ្ជាក់គោត្តនាម និងនាម)........................... |
| **៩. កំណត់ត្រាការសម្អាតប្រាក់ក្នុងរយៈពេលបីឆ្នាំចុងក្រោយ** |
| ☐មិនមាន<br>☐មាន (បើមានសូមបញ្ជាក់លម្អិត)................................................................................................ |
| **១០. មធ្យោបាយទំនាក់ទំនងករណីមានម៉ាជីនខល** |
| ☐លេខទូរសព្ទ.............................................. ☐ផ្ញើសារ..............................................<br>☐ទូរសារ.............................................. ☐អ៊ីម៉ែល..............................................<br>☐ផ្សេងៗ.............................................. |
| **១១. ទំនាក់ទំនងរបស់អតិថិជន** |
| ១. តើអតិថិជនមានទំនាក់ទំនងជាមួយនឹងអភិបាល ឬនិយោជិតរបស់ឈ្មួញជើងសាឧបករណ៍និស្សន្ទដែរ ឬទេ?<br>☐មិនមាន<br>☐មាន (ឈ្មោះអភិបាល ឬនិយោជិត.................................. ត្រូវជា..............................................)<br>២. តើអតិថិជនមានទំនាក់ទំនងជាមួយនឹងអភិបាល ឬនិយោជិតរបស់ក្រុមហ៊ុនសមភាគីកណ្ដាលដែលឈ្មួញជើងសាឧបករណ៍និស្សន្ទជាភ្នាក់ងារដែរ ឬទេ?<br>☐មិនមាន<br>☐មាន (ឈ្មោះអភិបាល ឬនិយោជិត.................ត្រូវជា.............. ឈ្មោះក្រុមហ៊ុនសមភាគីកណ្ដាល ................) |
| **១២. ឯកសារភ្ជាប់សម្រាប់ការស្នើសុំបើកគណនី** |
| ☐អត្តសញ្ញាណប័ណ្ណថតចម្លង ☐សៀវភៅគ្រួសារថតចម្លង<br>☐លិខិតឆ្លងដែន ឬទិដ្ឋការថតចម្លង ☐ផ្សេងៗ.............................................. |
| **១៣. បុគ្គលដែលអាចទាក់ទងបានក្នុងករណីចាំបាច់** |
| គោត្តនាម និងនាម.............................. អក្សរឡាតាំង.............................. ត្រូវជា .............................. |

| |
|---|
| អាសយដ្ឋាន.............................................................................................................................................. |
| .............................................................................................................................................. |
| លេខទូរសព្ទ........................................................................ អ៊ីម៉ែល................................................................ |
| **១៤. យោបល់របស់ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ** |
| .............................................................................................................................................. |
| .............................................................................................................................................. |
| .............................................................................................................................................. |
| ខ្ញុំសូមធានាថាព័ត៌មានដែលខ្ញុំបានផ្តល់ជូនខាងលើនេះ គឺជាព័ត៌មានដែលពិតប្រាកដ និងត្រឹមត្រូវទាំងស្រុង។ ខ្ញុំសូមសន្យាថានឹងទទួលខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយដែលផ្តល់ជូន ជាព័ត៌មានមិនពិត ឬនាំឱ្យយល់ខុស។ នៅពេលចុះហត្ថលេខានៅលើពាក្យស្នើសុំនេះ ខ្ញុំបានយល់ដឹងពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទ។ ខ្ញុំយល់ព្រមអនុវត្តច្បាប់ និងបទប្បញ្ញត្តិដែលទាក់ទងនឹងការជួញដូរឧបករណ៍និស្សន្ទឱ្យបានខ្ជាប់ខ្ជួន និងយល់ព្រមឱ្យក្រុមហ៊ុនត្រួតពិនិត្យ និងបង្ហាញព័ត៌មានរបស់ខ្ញុំទៅ គ.ម.ក. ក្រុមហ៊ុនសមភាគីកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ច។ |

| | | |
|---|---|---|
| ហត្ថលេខារបស់ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ<br>កាលបរិច្ឆេទ | ហត្ថលេខារបស់អ្នកគ្រប់គ្រងសាខា ឬនាយកប្រតិបត្តិ និងត្រាឈ្មួញជើងសាឧបករណ៍និស្សន្ទ<br>កាលបរិច្ឆេទ | ហត្ថលេខារបស់អតិថិជន<br>កាលបរិច្ឆេទ |

## ខ. ពាក្យស្នើសុំបើកគណនីជួញដូរឧបករណ៍និស្សន្ទ (សម្រាប់នីតិបុគ្គល)

| | | |
|---|---|---|
| ឈ្មោះឈ្មួញជើងសាឧបករណ៍និស្សន្ទ........................ | កាលបរិច្ឆេទនៃការស្នើសុំ | លេខគណនី |
| ឈ្មោះភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ...................... | ................................. | ................................. |
| **១. ព័ត៌មានអតិថិជន** | | |
| ឈ្មោះនីតិបុគ្គល (ជាភាសាខ្មែរ) .........................................(ជាភាសាអង់គ្លេស) ............................................. | | |
| លេខចុះបញ្ជីពាណិជ្ជកម្ម.................................... | កាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម............................. | |
| កាលបរិច្ឆេទផុតសុពលភាពវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ............................................ | | |
| លេខអត្តសញ្ញាណកម្មសារពើពន្ធ............................ | សញ្ជាតិ ................................................. | |
| ប្រភេទក្រុមហ៊ុន............................................ | ប្រភេទអាជីវកម្ម........................................ | |

ធ្លាប់ចុះបញ្ជីក្នុងទីផ្សារមូលបត្រ÷ ☐មិនធ្លាប់ ☐ធ្លាប់ នៅថ្ងៃទី......../.........../........... | លេខកូដ..................

អាសយដ្ឋាន........................................................................................................................................

..........................................................................................................................................................

ឈ្មោះអ្នកតំណាងនីតិបុគ្គល (ជាភាសាខ្មែរ) ...................................... (ជាភាសាអង់គ្លេស) ................................

ថ្ងៃ ខែ ឆ្នាំកំណើត ....................... ភេទ......... សញ្ជាតិ........... ស្ថានភាពគ្រួសារ .............. តួនាទី.................

លេខអត្តសញ្ញាណប័ណ្ណ/ លិខិតឆ្លងដែន................................. កាលបរិច្ឆេទផុតសុពលភាព..........................

ទូរសព្ទ....................................... | ទូរសារ............................ | អ៊ីម៉ែល ........................................

អាសយដ្ឋាន........................................................................................................................................

មូលធនចុះបញ្ជី.....................................................................................................................................

ចំណូលចំបងរបស់អាជីវកម្ម (សូមបញ្ជាក់) ..........................................................................................

ចំណូលសរុបចុងក្រោយ........................................................... រៀល | ក្នុងឆ្នាំ (ខែ/ឆ្នាំ) ..........................

ឈ្មោះអភិបាលប្រតិបត្តិ ឬ អគ្គនាយក ឬ នាយកប្រតិបត្តិ...................................................................................

**២. បុគ្គលជាប់ទាក់ទង (សូមភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ/ លិខិតឆ្លងដែន ថតចម្លងរបស់បុគ្គលជាប់ទាក់ទងនោះ)**

បុគ្គលគ្រប់គ្រង (Controlling Person): ☐ផ្ទាល់ខ្លួន ☐បុគ្គលផ្សេង (បញ្ជាក់គោត្តនាម និងនាម)............................

ឈ្មោះបុគ្គលទទួលបានការអនុញ្ញាតចុះហត្ថលេខាបើកគណនី...........................................................................

ឈ្មោះបុគ្គលទទួលបានការអនុញ្ញាតក្នុងការជួញដូរឧបករណ៍និស្សន្ទជិន្នូសក្រុមហ៊ុន

| ល.រ | នាម និងគោត្តនាម | តួនាទី | លេខទូរសព្ទ | ទូរសារ | អ៊ីម៉ែល |
|---|---|---|---|---|---|
| ១. | | | | | |
| ២. | | | | | |
| ៣. | | | | | |

មធ្យោបាយទាក់ទងករណីមានម៉ាជីនខល÷

សូមទាក់ទងបុគ្គលដែលបានទទួលការអនុញ្ញាតទី......... ខាងលើ តាមរយៈ ☐ទូរសព្ទ ☐ទូរសារ ☐សារទូរសព្ទ ☐អ៊ីម៉ែល

**៣. ភាគហ៊ុនិក**

ភាគហ៊ុនិកចំបង (ភាគហ៊ុនិកដែលកាន់កាប់៣០% ឬច្រើនជាងនេះ)

| | |
|---|---|
| ១. ........................................................................ | គិតភាគរយនៃចំនួនដើមទុនចុះបញ្ជី............................. |
| ២. ........................................................................ | គិតភាគរយនៃចំនួនដើមទុនចុះបញ្ជី............................. |
| ៣. ........................................................................ | គិតភាគរយនៃចំនួនដើមទុនចុះបញ្ជី............................. |

| ៤. ប្រាក់ចំណេញប្រចាំឆ្នាំ |
|---|
| ប្រាក់ចំណេញបន្ទាប់ពីដកពន្ធ (រៀល)<br>☐ 0 - ២០០.០០០.០០០<br>☐ ២០០.០០០.០០១ - ៤០០.០០០.០០០<br>☐ ៤០០.០០០.០០១ - ៦០០.០០០.០០០<br>☐ ច្រើនជាង ៦០០.០០០.០០០ |
| ប្រភពចំណូលផ្សេងទៀត ប្រសិនបើមាន<br>☐ ភាគលាភ/ការប្រាក់ពីមូលបត្រកម្មសិទ្ធិ/សញ្ញាបណ្ណ<br>☐ ការប្រាក់ពីធនាគារ<br>☐ ផ្សេងទៀត .................. |

| ៥. គោលដៅនៃការវិនិយោគ | | |
|---|---|---|
| ☐ការវិនិយោគរយៈពេលខ្លី | ☐ការវិនិយោគរយៈពេលវែង | ☐ផ្សេងៗ........................................ |

| ៦. បទពិសោធន៍វិនិយោគ | | | |
|---|---|---|---|
| បទពិសោធន៍នៃការជួញដូរនៅក្នុងទីផ្សារហិរញ្ញវត្ថុដទៃទៀត | | ☐មិនមាន | ☐មាន |
| ១. ឈ្មោះទីផ្សារ.................. | ប្រភេទផលិតផល.......... | ប្រទេស............. | ឆ្នាំនៃការវិនិយោគ.......... ឆ្នាំ |
| ២. ឈ្មោះទីផ្សារ.................. | ប្រភេទផលិតផល.......... | ប្រទេស............. | ឆ្នាំនៃការវិនិយោគ.......... ឆ្នាំ |

| ៧. វិនិយោគិនគុណវុឌ្ឍិ |
|---|
| តើអតិថិជនជាវិនិយោគិនគុណវុឌ្ឍិដែរ ឬទេ?<br>☐មិនមែន ☐មែន<br>បើមែន សូមបញ្ជាក់÷<br>☐អតិថិជនមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ២.០០០.០០០.០០០ រៀល ដែលមានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុចុងក្រោយ ឬ<br>☐អតិថិជនមានចំណូលប្រចាំឆ្នាំយ៉ាងតិច ៥០០.០០០.០០០ រៀល ក្នុងរយៈពេល ២ ឆ្នាំចុងក្រោយ ឬ<br>☐អតិថិជនធ្លាប់ចូលរួមវិនិយោគក្នុងវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា យ៉ាងតិច ២០០.០០០.០០០ រៀល |

| ៨. កំណត់ត្រាការសម្អាតប្រាក់ក្នុងរយៈពេលបីឆ្នាំចុងក្រោយ |
|---|
| ☐មិនមាន<br>☐មាន (បើមានសូមបញ្ជាក់លម្អិត) |

## ៩. ឯកសារភ្ជាប់សម្រាប់ការស្នើសុំបើកគណនី

☐អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែនរបស់អ្នកតំណាង ☐វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

☐បណ្ណប៉ាតង់ ☐វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម

☐លិខិតផ្ទេរសិទ្ធិក្នុងការជួញដូរឧបករណ៍និស្សន្ទជំនួសក្រុមហ៊ុន ☐លិខិតផ្ទេរសិទ្ធិចុះហត្ថលេខាបើកគណនី

☐ផ្សេងៗ............................................

## ១០. បុគ្គលទំនាក់ទំនងក្នុងករណីចាំបាច់

១. ឈ្មោះ........................ ភេទ........ តួនាទី............... លេខទូរសព្ទ............... អ៊ីម៉ែល ........................

២. ឈ្មោះ........................ ភេទ........ តួនាទី............... លេខទូរសព្ទ............... អ៊ីម៉ែល ........................

៣. ឈ្មោះ........................ ភេទ........ តួនាទី............... លេខទូរសព្ទ............... អ៊ីម៉ែល ........................

## ១១. យោបល់របស់ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ

........................................................................................................................................

........................................................................................................................................

........................................................................................................................................

ខ្ញុំសូមធានាថាព័ត៌មានដែលខ្ញុំបានផ្តល់ជូនខាងលើនេះ គឺជាព័ត៌មានដែលពិតប្រាកដ និងត្រឹមត្រូវទាំងស្រុង។ ខ្ញុំសូមសន្យាថានឹងទទួលខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយដែលផ្តល់ជូន ជាព័ត៌មានមិនពិត ឬនាំឱ្យយល់ខុស។ នៅពេលចុះហត្ថលេខានៅលើពាក្យស្នើសុំនេះ ខ្ញុំបានយល់ដឹងពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទ។ ខ្ញុំយល់ព្រមអនុវត្តច្បាប់ និងបទប្បញ្ញត្តិដែលទាក់ទងនឹងការជួញដូរឧបករណ៍និស្សន្ទឱ្យបានខ្ជាប់ខ្ជួន និងយល់ព្រមឱ្យក្រុមហ៊ុនត្រួតពិនិត្យ និងបង្ហាញព័ត៌មានរបស់ខ្ញុំទៅ គ.ម.ក. ក្រុមហ៊ុនសមភាគីកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ច។

| | | |
|---|---|---|
| ហត្ថលេខារបស់ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ<br>កាលបរិច្ឆេទ | ហត្ថលេខារបស់អ្នកគ្រប់គ្រងសាខា ឬនាយកប្រតិបត្តិ និងត្រាឈ្មួញជើងសាឧបករណ៍និស្សន្ទ<br>កាលបរិច្ឆេទ | ហត្ថលេខារបស់អតិថិជន (បុគ្គលទទួលបានការអនុញ្ញាត) និងត្រាក្រុមហ៊ុន<br>កាលបរិច្ឆេទ |

ឧបសម្ព័ន្ធ ២ នៃគោលការណ៍ណែនាំលេខ...០០៩/១៧
ស្តីពីទម្រង់ពាក្យស្នើសុំបើកគណនីជួញដូរ និងកិច្ចព្រមព្រៀងអតិថិជនសម្រាប់ការជួញដូរឧបករណ៍និស្សន្ទ
ចុះថ្ងៃទី..២៧..ខែ..វិច្ឆិកា..ឆ្នាំ..២០១៧....

# កិច្ចព្រមព្រៀងអតិថិជនសម្រាប់ការជួញដូរឧបករណ៍និស្សន្ទ

*ទីកន្លែងធ្វើកិច្ចព្រមព្រៀង*

កិច្ចព្រមព្រៀងរវាង

**-ក្រុមហ៊ុន÷**

ឈ្មោះ.................................ដែលមានអាសយដ្ឋាន........................................................

ជាឈ្មួញជើងសាឧបករណ៍និស្សន្ទទទួលបានអាជ្ញាបណ្ណលេខ.................................................

ចេញដោយគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.)

និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទឈ្មោះ........................ទទួលបានអាជ្ញាបណ្ណលេខ..............

ចេញដោយ គ.ម.ក.

ជាមួយ

**-អតិថិជន÷**

ឈ្មោះ.................................ដែលមានអាសយដ្ឋាន........................................................

លេខអត្តសញ្ញាណបណ្ណ/លេខលិខិតឆ្លងដែន..................................លេខបញ្ជីពាណិជ្ជកម្ម (ករណីជាស្ថាប័ន) ...........................ថ្ងៃទី..........ខែ............ឆ្នាំ...............។

## ភាគីទាំងពីរបានព្រមព្រៀងដូចតទៅ

### ១. និយមន័យ

**ឧបករណ៍និស្សន្ទ** (Derivative Instrument)÷ សំដៅដល់កិច្ចសន្យាលើគម្លាតថ្លៃ (Contract For Difference)នៃឧបករណ៍ហិរញ្ញវត្ថុដើមដែលចេញពីមូលបត្រកម្មសិទ្ធិ មូលបត្របំណុល សន្ទស្សន៍ លោហៈធាតុមានតម្លៃ ប្រេងឆៅ ឧស្ម័នធម្មជាតិ កសិផល រូបិយបណ្ណ រួមទាំងគម្រោងការពារថ្លៃដើម(Principal Protected Scheme) ជាដើមនិងដែលត្រូវបានជួញដូរក្នុងទីផ្សារ។ ឧបករណ៍និស្សន្ទទាំងនេះគឺជាឧបករណ៍ហិរញ្ញវត្ថុដែលជាប្រភេទមួយនៃមូលបត្រ។

**អាជីវកម្មជើងសាឧបករណ៍និស្សន្ទ** (Derivative Brokerage Business)÷ សំដៅដល់អាជីវកម្មផ្តល់សេវាសម្រាប់ការជួញដូរឧបករណ៍និស្សន្ទក្នុងនាមជាភ្នាក់ងាររបស់អតិថិជនខ្លួន។

ក្រុមហ៊ុនសមភាគីកណ្តាល (Central Counterparty)÷ សំដៅដល់ក្រុមហ៊ុនដែលធ្វើជាដៃគូភ្ជាប់ចំពោះរាល់កិច្ចសន្យាជួញដូរលើឧបករណ៍និស្សន្ទមួយ ឬច្រើន ពោលគឺក្លាយជាភាគីអ្នកទិញចំពោះរាល់អ្នកលក់ និងក្លាយជាភាគីអ្នកលក់ចំពោះរាល់អ្នកទិញ។

**គម្លាតថ្លៃ (Spread)**÷ សំដៅដល់គម្លាតរវាងថ្លៃទិញ និងថ្លៃលក់នៃផលិតផល។

**ច្បាប់ (Law)**÷ សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ឈ្មួញជើងសាឧបករណ៍និស្សន្ទ (Derivative Broker)**÷ សំដៅដល់ក្រុមហ៊ុនដែលត្រូវទទួលបានអាជ្ញាបណ្ណ ឬក្រុមហ៊ុនមូលបត្រដែលត្រូវទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក. ដើម្បីធ្វើអាជីវកម្មជើងសាឧបករណ៍និស្សន្ទ។

**ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ (Derivative Representative)**÷ សំដៅដល់រូបវន្តបុគ្គលដែលត្រូវទទួលអាជ្ញាបណ្ណពីអគ្គនាយកនៃ គ.ម.ក. ដើម្បីបើកនិងគ្រប់គ្រងគណនីឲ្យអតិថិជន និងផ្តល់សេវាផ្សេងទៀតក្នុងនាមឈ្មួញជើងសាឧបករណ៍និស្សន្ទ។

**ម៉ាជីនដំបូង (Initial Margin)**÷ សំដៅដល់ទំហំសាច់ប្រាក់ដំបូងដែលត្រូវបានកំណត់គិតជាភាគរយនៃទំហំវិនិយោគសរុបដែលអតិថិជនត្រូវដាក់តម្កល់ជាចាំបាច់ក្នុងគណនីមុនធ្វើការជួញដូរ។

**អនុក្រឹត្យ (Anukret)**÷ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**២.លក្ខខណ្ឌទូទៅ**

១. អតិថិជនព្រមព្រៀងឲ្យក្រុមហ៊ុនបម្រើសេវាកម្មជាភ្នាក់ងាររបស់អតិថិជន និងមានសិទ្ធិក្នុងការធ្វើសកម្មភាពដែលទាក់ទងនឹងការជួញដូរឧបករណ៍និស្សន្ទក្នុងនាមអតិថិជន។ អតិថិជនព្រមព្រៀងអនុវត្តកាតព្វកិច្ចនានាដែលកើតចេញពីការអនុវត្តអាណត្តិដោយក្រុមហ៊ុន ក្នុងដែនអនុញ្ញាតដែលផ្តល់ដោយអតិថិជនក្រោមកិច្ចព្រមព្រៀងនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

២. ក្រុមហ៊ុនមិនត្រូវធ្វើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទក្នុងគណនីអតិថិជន ក្នុងនាមអតិថិជនដោយមិនមានការយល់ព្រមជាមុនពីអតិថិជនឡើយ។

៣. ក្រុមហ៊ុនធានាថា ក្រុមហ៊ុនបានទទួលអាជ្ញាបណ្ណពី គ.ម.ក. ក្នុងការផ្តល់សេវាកម្មជូនអតិថិជន។

៤. ភាគីទាំងពីរទទួលស្គាល់ និងព្រមព្រៀងថាការបង់លាភការឲ្យក្រុមហ៊ុនដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានកំណត់តាមតារាង [១] និងអាចប្រែប្រួលតាមការកំណត់របស់ គ.ម.ក.។ ក្រុមហ៊ុនអាចធ្វើបច្ចុប្បន្នកម្មតារាង[១] នៅពេលមានការផ្លាស់ប្តូរលាភការ និងត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរអំពីការផ្លាស់ប្តូរនោះ។ ការតម្លើងលាភការដែលត្រូវបង់ដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ មានសុពលភាពអនុវត្ត លុះត្រាតែកិច្ចព្រមព្រៀងនេះបានធ្វើបច្ចុប្បន្នកម្ម ហើយអតិថិជនបានជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងការយល់ព្រម។

៥. អតិថិជនបានអាន និងយល់ច្បាស់ពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ព្រមទាំងលក្ខខណ្ឌទូទៅនៃការជួញដូរឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុន និងធានាថាអនុវត្តទៅតាមច្បាប់ និងបទប្បញ្ញត្តិ ព្រមទាំងលក្ខខណ្ឌទូទៅនេះ។

៦. អតិថិជនយល់ព្រមផ្តល់ជូនក្រុមហ៊ុននូវ÷

ក. ព័ត៌មានស្តីពីអត្តសញ្ញាណពិតប្រាកដរបស់អតិថិជន និងអ្នកទទួលផលប្រយោជន៍ពីអតិថិជន។

ខ. គោលដៅនៃការជួញដូររបស់អតិថិជន។

គ. ព័ត៌មានស្ដីពីការជួញដូររបស់អតិថិជនក្នុងក្រុមហ៊ុន ឬក្រុមហ៊ុនផ្សេង និងព័ត៌មានស្ដីពីការជួញដូរឧបករណ៍និស្សន្ទដែលអតិថិជនកំពុងជួញដូរ។

ឃ. នៅពេលដែលអតិថិជនធ្វើការបញ្ជូនបញ្ជាការជួញដូរសម្រាប់បុគ្គលផ្សេងទៀត អតិថិជនយល់ព្រមផ្ដល់ព័ត៌មានដូចមានចែងក្នុងចំណុច ក ខ និង គ ខាងលើ របស់បុគ្គលនោះ។

៧. ភាគីទាំងពីរព្រមព្រៀងថា ការជួញដូរឧបករណ៍និស្សន្ទត្រូវធ្វើឡើងអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

៨. ក្រុមហ៊ុនត្រូវផ្ដល់ជូនអតិថិជននូវរបាយការណ៍ស្ដីពីប្រតិបត្តិការនៃការជួញដូរឧបករណ៍និស្សន្ទ ព្រមទាំងស្ថានភាព និងបម្រែបម្រួលនៃមូលនិធិរបស់អតិថិជនក្នុងថ្ងៃជួញដូរ បន្ទាប់ពីកាលបរិច្ឆេទនៃប្រតិបត្តិការរបស់អតិថិជន និងត្រូវរៀបចំរបាយការណ៍ជួញដូរឧបករណ៍និស្សន្ទដើម្បីជូនដំណឹងពីសមតុល្យសាច់ប្រាក់ ស្ថានភាពជួញដូរឧបករណ៍និស្សន្ទ និងម៉ាជីនរបស់អតិថិជន ដើម្បីឱ្យអតិថិជនបានដឹង និង/ឬផ្ទៀងផ្ទាត់ជាមួយប្រព័ន្ធដែលបង្កើតឡើងដោយក្រុមហ៊ុនក្នុងអំឡុងពេលម៉ោងធ្វើការ។ របាយការណ៍នេះត្រូវផ្ដល់ជូនអតិថិជនតាមរយៈលាយលក្ខណ៍អក្សរ សារអេឡិចត្រូនិច ឬមធ្យោបាយអេឡិចត្រូនិចផ្សេងទៀត ដែលត្រូវបានការយល់ព្រមពីអតិថិជនជាមុន។

## ៣. ការជួញដូរឧបករណ៍និស្សន្ទ

១. អតិថិជនយល់ព្រមដាក់តម្កល់ប្រាក់ ឬទ្រព្យសម្បត្តិគ្រប់គ្រាន់សម្រាប់ធានាមុនពេលធ្វើការជួញដូរឧបករណ៍និស្សន្ទម្ដងៗ។

២. ដើម្បីដាក់បញ្ជាលក់ ឬទិញឧបករណ៍និស្សន្ទតាមរយៈកិច្ចព្រមព្រៀងនេះ អតិថិជនត្រូវយល់ដឹងឱ្យច្បាស់ពីប្រភេទផ្សេងៗ និងលក្ខខណ្ឌនៃបញ្ជាទិញ ឬលក់ដែលកំណត់ដោយក្រុមហ៊ុនសមភាគីកណ្ដាល អនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងវិធានជាធរមាន។

៣. បញ្ជាទិញ ឬលក់អាចធ្វើឡើងតាមរយៈឯកសារជាលាយលក្ខណ៍អក្សរ សម្លេង សារអេឡិចត្រូនិច ឬមធ្យោបាយអេឡិចត្រូនិចផ្សេងទៀត។ នៅពេលទទួលបញ្ជាពីអតិថិជន ក្រុមហ៊ុនត្រូវធ្វើកំណត់ត្រាបញ្ជានោះក្នុងទម្រង់ជាឯកសារជាលាយលក្ខណ៍អក្សរ ឬថតសម្លេង ឬតាមប្រព័ន្ធអេឡិចត្រូនិច ដើម្បីផ្ទៀងផ្ទាត់បញ្ជារបស់អតិថិជន។ ករណីការដាក់បញ្ជាលក់ ឬទិញឧបករណ៍និស្សន្ទធ្វើឡើងតាមរយៈទូរសព្ទ អតិថិជនយល់ព្រមអនុញ្ញាតឱ្យក្រុមហ៊ុនថតសម្លេងទាក់ទងនឹងបញ្ជាលក់ ឬទិញតាមរយៈទូរសព្ទ ដើម្បីឱ្យក្រុមហ៊ុនទុកជាភស្ដុតាង។

៤. ក្រុមហ៊ុនត្រូវធានាឱ្យមាននូវយន្តការប្រកបដោយប្រសិទ្ធភាពក្នុងការទទួលបញ្ជាទិញ ឬលក់ពីអតិថិជន។

៥. ក្រុមហ៊ុនត្រូវផ្ដល់ព័ត៌មានដល់អតិថិជនអំពីហានិភ័យផ្សេងៗ ដែលអាចកើតមាន ពេលដាក់បញ្ជាទិញ ឬលក់ និងក្រុមហ៊ុនត្រូវទទួលខុសត្រូវលើហានិភ័យនៃការរអាក់រអួលប្រព័ន្ធទូរសព្ទ អ៊ីនធឺណែត ឬប្រព័ន្ធជួញដូរផ្ទៃក្នុងរបស់ក្រុមហ៊ុនក្នុងពេលទទួលបញ្ជាទិញ ឬលក់ពីអតិថិជន។

៦. ក្រុមហ៊ុនធានាកាត់បន្ថយជាអតិបរមានូវហានិភ័យដែលអាចកើតមានឡើងពាក់ព័ន្ធនឹងការបញ្ជាទិញ ឬលក់។

៧. ក្រុមហ៊ុនត្រូវជូនដំណឹងភ្លាមៗដល់អតិថិជន ក្នុងករណីក្រុមហ៊ុនដឹងថាមានបុគ្គលដែលមិនបានទទួលសិទ្ធិបញ្ជាទិញ ឬលក់ ប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជនដើម្បីដាក់បញ្ជាទិញ ឬលក់។

៨. អតិថិជនត្រូវទទួលស្គាល់ថាបានសិក្សា និងយល់ដឹងច្បាស់លាស់អំពីហានិភ័យដែលអាចកើតឡើងក្នុងការដាក់បញ្ជាទិញ ឬលក់ដែលក្រុមហ៊ុនបានផ្តល់ព័ត៌មាន។

៩. អតិថិជនត្រូវជូនដំណឹងភ្លាមដល់ក្រុមហ៊ុន ក្នុងករណីអតិថិជនដឹងថាមានបុគ្គលដែលមិនបានទទួលសិទ្ធិបញ្ជាទិញ ឬលក់ប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជនដើម្បីដាក់បញ្ជាទិញ ឬលក់។

១០. អតិថិជនទទួលស្គាល់ និងយល់ព្រមថាការទិញ ឬលក់ឧបករណ៍និស្សន្ទតាមរយៈឈ្មួញជើងសាឧបករណ៍និស្សន្ទ គឺជាការទិញ ឬលក់រវាងអតិថិជនជាមួយក្រុមហ៊ុនសមភាគីកណ្តាល ដែលជាភាគីម្ខាងទៀតនៃកិច្ចសន្យាដែលក្រុមហ៊ុនជាភ្នាក់ងារ។

**៤. ម៉ាជីន**

១. អតិថិជនយល់ព្រមដាក់តម្កល់សាច់ប្រាក់ជាមួយក្រុមហ៊ុន ក្នុងគោលបំណងធ្វើការជួញដូរឧបករណ៍និស្សន្ទទៅតាមម៉ាជីនដែលកំណត់ដោយក្រុមហ៊ុន អនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងវិធានជាធរមាន ក្នុងទំហំសាច់ប្រាក់មិនលើសពី ២០០.០០០.០០០ (ពីររយលាន) រៀល ឬ ៥០.០០០ (ហាសិបពាន់) ដុល្លារអាមេរិក លើកលែងតែអតិថិជននោះជាវិនិយោគិនគុណវុឌ្ឍិដែលបំពេញលក្ខខណ្ឌតាមច្បាប់ និងប្បញ្ញត្តិជាធរមាន។

២. ក្រុមហ៊ុនត្រូវដាក់សាច់ប្រាក់អតិថិជនក្នុងគណនីដាច់ដោយឡែកពីគណនីរបស់ក្រុមហ៊ុននៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក.។

៣. ក្រុមហ៊ុននឹងគណនាតម្លៃនៃឧបករណ៍និស្សន្ទនៅក្នុងគណនីរបស់អតិថិជន និងកែតម្រូវម៉ាជីនដែលបានដាក់តម្កល់ដោយអតិថិជននៅក្រុមហ៊ុន យ៉ាងយូរត្រឹមចុងថ្ងៃជួញដូរដើម្បីឱ្យកម្រិតម៉ាជីននៅក្នុងគណនីរបស់អតិថិជនស្របតាមច្បាប់ បទប្បញ្ញត្តិ និងវិធានជាធរមាន។

៤. អតិថិជនយល់ព្រមអនុវត្តម៉ាជីនរក្សាដែលកំណត់ដោយក្រុមហ៊ុនអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងវិធានជាធរមាន។ ប្រសិនកម្រិតម៉ាជីនរបស់អតិថិជនទាបជាងម៉ាជីនរក្សា អតិថិជនត្រូវពិនិត្យពីភាពគ្រប់គ្រាន់នៃកម្រិតម៉ាជីនដូចដែលក្រុមហ៊ុនបានជូនដំណឹងទៅអតិថិជនតាមរយៈមធ្យោបាយដែលទទួលយល់ព្រមជាមុនពីអតិថិជនដូចជា លិខិតជាលាយលក្ខណ៍អក្សរ ទូរសារ ទូរសព្ទ អ៊ីម៉ែល ឬមធ្យោបាយអេឡិចត្រូនិចផ្សេងៗទៀត និងអតិថិជនត្រូវដាក់សាច់ប្រាក់បំពេញបន្ថែម ដើម្បីឱ្យកម្រិតម៉ាជីនក្នុងគណនីរបស់អតិថិជនមិនទាបជាងម៉ាជីនដំបូង។ អតិថិជនត្រូវដាក់សាច់ប្រាក់បំពេញបន្ថែមម៉ាជីននៅក្នុងអំឡុងពេលជាក់លាក់ណាមួយដែលកំណត់ដោយក្រុមហ៊ុន។

៥. អតិថិជនអាចដកសាច់ប្រាក់ដែលបានដាក់តម្កល់ក្នុងករណីកម្រិតម៉ាជីនក្នុងគណនីរបស់អតិថិជនខ្ពស់ជាងម៉ាជីនដំបូង។

៦. ករណីក្រុមហ៊ុនមិនបានទទួលសាច់ប្រាក់បន្ថែមពីអតិថិជនក្នុងរយៈពេលដែលបានកំណត់ ក្រុមហ៊ុនមានសិទ្ធិដូចខាងក្រោម÷

ក. បដិសេធការដាក់បញ្ជាទិញ ឬលក់បន្ថែមរបស់អតិថិជន។

ខ. បិទរាល់ស្ថានភាពជួញដូរទាំងអស់ ឬមួយផ្នែករបស់អតិថិជន។

៧. ក្រុមហ៊ុនមិនត្រូវដកសាច់ប្រាក់របស់អតិថិជនឡើយ លើកលែងករណីដូចខាងក្រោម÷

ក. ក្រុមហ៊ុនធ្វើការទូទាត់ឱ្យបុគ្គលណាមួយដែលមានសិទ្ធិ។

ខ. នៅពេលអតិថិជនធ្វើការជួញដូរឧបករណ៍និស្សន្ទ ក្រុមហ៊ុនមានកាតព្វកិច្ចទូទាត់ក្នុងនាមអតិថិជនដែលទុកសាច់ប្រាក់ក្នុងគណនីនោះ។

គ. ក្រុមហ៊ុនធ្វើការទូទាត់ថ្លៃសេវា កម្រៃជើងសា និងបន្ទុកចំណាយផ្សេងទៀតដែលអតិថិជនត្រូវបង់។

ឃ. ក្រុមហ៊ុនធ្វើការទូទាត់ឱ្យបុគ្គល ឬគណនីផ្សេងយោងតាមការស្នើសុំរបស់អតិថិជនតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ។

ង. ក្រុមហ៊ុនធ្វើការទូទាត់ ឬដកសាច់ប្រាក់ដែលតម្រូវដោយ គ.ម.ក. ឬច្បាប់។

## ៥. ការមិនការជួញដូរឧបករណ៍និស្សន្ទ

១. ក្រុមហ៊ុនអាចចាត់វិធានការចំពោះអតិថិជន ប្រសិនបើមានស្ថានភាពណាមួយដូចខាងក្រោម÷

ក. អតិថិជនបានលាក់បាំង ឬផ្តល់ព័ត៌មានមិនពិត។

ខ. អតិថិជនមិនអនុវត្តតាមប្រការណាមួយនៃកិច្ចព្រមព្រៀងនេះ។

គ. ក្រុមហ៊ុនយល់ថា មានភាពចាំបាច់ក្នុងការបង្ការស្ថានភាពជួញដូរមិនប្រក្រតី ឬមានការអនុវត្តការជួញដូរឧបករណ៍និស្សន្ទមិនត្រឹមត្រូវ ឬអាចល្មើសច្បាប់។

ឃ. ក្រុមហ៊ុនអនុវត្តតាមការតម្រូវរបស់ គ.ម.ក.។

២. វិធានការដែលក្រុមហ៊ុនអាចចាត់ចំពោះអតិថិជនដូចខាងក្រោម÷

ក. បិទស្ថានភាពជួញដូរណាមួយ ឬបិទស្ថានភាពជួញដូរទាំងអស់របស់អតិថិជន ក្នុងគោលបំណងទូទាត់កាតព្វកិច្ចរបស់អតិថិជន។

ខ. កាត់បន្ថយ ឬដាក់កំហិតលើការជួញដូរឧបករណ៍និស្សន្ទរបស់អតិថិជន។

## ៦. ផលប្រយោជន៍ និងទំនាក់ទំនង

ក្រុមហ៊ុនត្រូវបញ្ជាក់រាល់ផលប្រយោជន៍ និងទំនាក់ទំនងទាំងអស់រវាងក្រុមហ៊ុន និងបុគ្គលផ្សេងទៀតដែលអាចមានឥទ្ធិពលដល់ក្រុមហ៊ុន ឬភ្នាក់ងារជើងសាឧបករណ៍និស្សន្ទក្នុងតារាង [២] ដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង និងបទប្បញ្ញត្តិពាក់ព័ន្ធ។

### ៧. ការតវ៉ា

១. ករណីក្រុមហ៊ុន ឬភ្នាក់ងារជើងសាឧបករណ៍និស្សន្ទមិនអនុវត្តតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ អតិថិជនអាចធ្វើបណ្តឹងជាលាយលក្ខណ៍អក្សរដោយត្រូវមានបញ្ជាក់ឈ្មោះ និងព័ត៌មានលម្អិតនៃបុគ្គលដោះស្រាយការតវ៉ារបស់ក្រុមហ៊ុន។

២. ក្រុមហ៊ុនត្រូវយល់ព្រមដោះស្រាយវិវាទរបស់អតិថិជនក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបណ្តឹង។

### ៨. ការរក្សាការសម្ងាត់

ក្រុមហ៊ុនយល់ព្រមថា មិនត្រូវដាក់បង្ហាញព័ត៌មានសម្ងាត់របស់អតិថិជន ឬព័ត៌មានសម្ងាត់ដទៃទៀតពាក់ព័ន្ធនឹងអតិថិជនដែលក្រុមហ៊ុនទទួលបានក្នុងក្របខ័ណ្ឌផ្តល់សេវាកម្មស្របតាមកិច្ចព្រមព្រៀងនេះ ទៅឱ្យបុគ្គលណាមួយឡើយ លើកលែងតែមានករណីណាមួយដូចខាងក្រោម÷

១. មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអតិថិជន ដោយមានបញ្ជាក់ពីបុគ្គលដែលមានសិទ្ធិទទួលព័ត៌មានសម្ងាត់នោះ។

២. មានការតម្រូវពី គ.ម.ក. ឬតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

៣. មានការតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

### ៩. ការជូនដំណឹង

១. រាល់របាយការណ៍ និងការជូនដំណឹងដែលផ្តល់ឱ្យអតិថិជនត្រូវស្របទៅតាមកិច្ចព្រមព្រៀងនេះ ឬច្បាប់ និងបទប្បញ្ញត្តិ លើកលែងតែមានសំណើជាលាយលក្ខណ៍អក្សរផ្សេងពីនេះពីអតិថិជន។

២. អតិថិជនព្រមព្រៀងជូនដំណឹងភ្លាមៗដល់ក្រុមហ៊ុននៅពេលមានការផ្លាស់ប្តូរអាសយដ្ឋាន ឬព័ត៌មានសម្រាប់ទំនាក់ទំនងផ្សេងទៀតរបស់ខ្លួន។ ករណីអតិថិជនខកខានមិនបានជូនដំណឹងដល់ក្រុមហ៊ុនពីការផ្លាស់ប្តូរទាំងនេះ រាល់របាយការណ៍ ឬការជូនដំណឹងត្រូវផ្ញើជូនអតិថិជនទៅកាន់អាសយដ្ឋានដែលក្រុមហ៊ុនបានដឹងចុងក្រោយ។

### ១០. កិច្ចព្រមព្រៀងរួម

រាល់បទបង្ហាញ ឬសេចក្តីថ្លែងការណ៍ ឬកិច្ចព្រមព្រៀងផ្សេងទៀតដែលមានខ្លឹមសារផ្ទុយពីកិច្ចព្រមព្រៀងនេះទោះជាលាយលក្ខណ៍អក្សរ ឬក៏ផ្ទាល់មាត់រវាងភាគីទាំងសងខាង មិនមានអានុភាពអនុវត្តឡើយ។

### ១១. ច្បាប់ចម្លងនៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះធ្វើឡើងជាពីរច្បាប់ ដែលមានចុះហត្ថលេខា និងត្រារបស់ក្រុមហ៊ុន ឬស្នាមម្រាមដៃរបស់ភាគីទាំងសងខាង ហើយក្រុមហ៊ុនត្រូវផ្តល់ឱ្យអតិថិជនមួយច្បាប់ភ្លាមៗ និងមួយច្បាប់ទៀតរក្សាទុកនៅក្រុមហ៊ុន។

**១២. ការកែប្រែ**

កិច្ចព្រមព្រៀងនេះ អាចកែប្រែនៅពេលមានការយល់ព្រមរវាងភាគីទាំងសងខាង។ នៅពេលមានការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលផ្ទុយទៅនឹងកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុនត្រូវកែប្រែកិច្ចព្រមព្រៀងនេះឱ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលបានធ្វើវិសោធនកម្មដោយមិនចាំបាច់មានការយល់ព្រមពីអតិថិជន និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អតិថិជនអំពីការកែប្រែកិច្ចព្រមព្រៀងនេះ។

**១៣. ការចាត់តាំង**

អតិថិជនព្រមព្រៀងថា រាល់សិទ្ធិ និងកាតព្វកិច្ចដែលមានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវផ្ទេរទៅឱ្យប្រតិសិទ្ធិសាកល ប្រតិសិទ្ធិដោយឡែក និងអ្នកតំណាងរបស់អតិថិជន ក្នុងករណីមានការផ្លាស់ប្តូរកម្មសិទ្ធិនៃទ្រព្យសម្បត្តិរបស់អតិថិជនដែលមាននៅក្នុងក្រុមហ៊ុនដែលកើតឡើងដោយប្រតិបត្តិនៃច្បាប់ ការទទួលមរណៈភាពរបស់អតិថិជន ក្ស័យធន អសមត្ថភាព ជីកាតុលាការ ឬដោយហេតុផលណាមួយផ្សេងទៀត។ ក្នុងករណីនេះ ក្រុមហ៊ុនត្រូវចាត់ចែងរាល់ការផ្ទេរទ្រព្យសម្បត្តិនោះ។

**១៤. ច្បាប់គ្រប់គ្រង**

១. កិច្ចព្រមពៀងនេះត្រូវស្ថិតនៅក្រោមច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

២. រាល់វិវាទដែលកើតចេញពីកិច្ចព្រមព្រៀងនេះអាចដោះស្រាយតាមនីតិវិធីដោះស្រាយវិវាទដែលកំណត់ដោយ គ.ម.ក.។

**១៥. ការបញ្ចប់កិច្ចព្រមព្រៀង**

១. ភាគីនីមួយៗមានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះគ្រប់ពេលវេលា ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ ដល់ភាគីម្ខាងទៀត។

២. ភាគីទាំងពីរយល់ព្រមថាការបញ្ចប់កិច្ចព្រមព្រៀងនេះ មិនប៉ះពាល់សិទ្ធិ និងកាតព្វកិច្ចព្រមទាំងផលប្រយោជន៍ដែលមិនទាន់អនុវត្តចប់របស់ភាគីនីមួយៗដែលមានមុនពេលបញ្ចប់កិច្ចព្រមព្រៀងនេះ។

**១៦. កត្តាហានិភ័យ**

១. អតិថិជនបានសិក្សាពីហានិភ័យពាក់ព័ន្ធនឹងការជួញដូរឧបករណ៍និស្សន្ទ និងបានយល់ដឹងពីការជួញដូរឧបករណ៍និស្សន្ទ យន្តការ និងការអនុវត្តការជួញដូរ ការដាក់សាច់ប្រាក់តម្កល់ក្នុងគណនី កត្តាហានិភ័យនិងព្យសនកម្មដែលជាលទ្ធផលបណ្តាលមកពីការជួញដូរឧបករណ៍និស្សន្ទ។ អតិថិជនក៏បានយល់ដឹងពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ រួមទាំងសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ភាគីនីមួយៗនៅក្នុងកិច្ចព្រមព្រៀងនេះ។

២. អតិថិជនយល់ដឹង និងទទួលស្គាល់ថា ការជួញដូរឧបករណ៍និស្សន្ទ គឺជាការជួញដូរមួយប្រភេទដែលមានហានិភ័យខ្ពស់ ដោយថ្លៃមានការប្រែប្រួលលឿន។

៣. មុនចុះហត្ថលេខាជាមួយអតិថិជន ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទដែលទាក់ទងដោយផ្ទាល់ជាមួយអតិថិជនបានពន្យល់ពីខ្លឹមសារនៃកិច្ចព្រមព្រៀងនេះដល់អតិថិជន និងបានពន្យល់លម្អិតអំពីវិធីសាស្ត្រនៃការដាក់បញ្ជាទាំងអស់ និងហានិភ័យដែលអាចកើតមានពាក់ព័ន្ធនឹងវិធីសាស្ត្រនៃការដាក់បញ្ជានីមួយៗដល់អតិថិជន។ ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទអាចផ្តល់ជូនអតិថិជននូវឯកសារផ្តល់ព័ត៌មានអំពីហានិភ័យ និងត្រូវពន្យល់លម្អិតអំពីហានិភ័យដែលអាចកើតមានពាក់ព័ន្ធនឹងការជួញដូរឧបករណ៍និស្សន្ទ។

កិច្ចព្រមព្រៀងនេះមានសុពលភាពចាប់ពីពេលភាគីទាំងពីរបានព្រមព្រៀងគ្នា ដោយមានចុះហត្ថលេខា ឬស្នាមម្រាមដៃខាងក្រោម៖

| | |
|---|---|
| ហត្ថលេខា ឬស្នាមម្រាមដៃ ឈ្មោះពេញ និងត្រា (ករណីស្ថាប័ន) របស់អតិថិជន<br><br>កាលបរិច្ឆេទ | ហត្ថលេខា ឬស្នាមម្រាមដៃឈ្មោះពេញ និងត្រា របស់ក្រុមហ៊ុន<br><br>កាលបរិច្ឆេទ |

## តារាងទី ១

## លាភការ

*ការកំណត់កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗ*

| ប្រភេទកម្រៃ | ចំនួនប្រាក់ | ការគណនា |
|---|---|---|
| កម្រៃជើងសា | | |
| ថ្លៃសេវា | | |
| លាភការផ្សេងៗ | | |

## តារាងទី ២

## ផលប្រយោជន៍ និងទំនាក់ទំនង

*ផលប្រយោជន៍ និងទំនាក់ទំនងដែលអាចមានឥទ្ធិពល*

| ឈ្មោះ | ទំនាក់ទំនងជាមួយក្រុមហ៊ុន | ការពន្យល់ពីឥទ្ធិពល |
|---|---|---|
| | | |
| | | |
| | | |